# សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

## យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស
## នៃអង្គការសហប្រជាជាតិ
## បណ្ដឹងលេខ ៤០២/១៩៩០

CCPR/C/44/D/402/1990

( **សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌** )

បកប្រែដោយ៖ លោក ស្រ៊ាង ចិន្តា
កែសម្រួលដោយ ៖ មាស បូរ៉ា
រចនាដោយ៖ អែម ចន្ទី

ឆ្នាំ ២០២១

# បណ្ដឹងលេខ ៤០២/១៩៩០

**ប្ដឹងដោយ:** Henricus Antonius Godefriedus Maria Brinkhof
(តំណាងដោយ មេធាវី) នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩០

**ជនរងគ្រោះត្រូវចោទ:** ដើមបណ្ដឹង

**រដ្ឋភាគី:** ប្រទេសហូឡង់

**ប្រកាសអាចទទួលយកបាន:** ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩២
(សម័យប្រជុំ លើកទី៤៤)

**កាលបរិច្ឆេទអនុម័តសេចក្ដីសម្រេច:** ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៣
(សម័យប្រជុំ លើកទី៤៨)

**កម្មវត្ថុ:** ការអនុញ្ញាតឲ្យអ្នកធ្វើសាក្សីរបស់ Jehovah រួចផុតពីការបម្រើការងារជាយោធានិងការងារជំនួស(ការរើសអើងចំពោះអ្នកប្រឆាំងបែបមនសិការ ដែលត្រូវចោទប្រកាន់)

**បញ្ហានីតិវិធី:** កង្វះការបញ្ជាក់ភ័ស្ដុតាងលើបណ្ដឹង (មិនអាចទទួលយកបាន ព្រោះខុសសមត្ថកិច្ចតាមប្រធានបទ *ratione materiae*) ស្ដីពីការប្រើប្រាស់ដំណោះស្រាយ ក្នុងស្រុកអស់លទ្ធភាព

**បញ្ហាសំខាន់:**ការប្រព្រឹត្តខុសគ្នា(លក្ខណៈវិនិច្ឆ័យប្រកបដោយហេតុ-ផលនិងការជំទាស់) អនុសាសន៍ក្នុងការពិនិត្យមើលច្បាប់ និងការអនុ-វត្តន៍នៅក្នុងស្រុកដែលពាក់ព័ន្ធ (*obiter dictum*)

**មាត្រានៃកតិកាសញ្ញាៈ** ១៤(១) និង ២៦

**មាត្រានៃពិធីសារបន្ថែមៈ** មាត្រា២ មាត្រា៣ និងមាត្រា៥(២)(ខ)

**១.** ដើមបណ្តឹង នៃបណ្តឹងនេះ គឺ Henricus A.G.M. Brinkhof ជាពលរដ្ឋនៃប្រទេសហូឡង់ កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៦២ រស់នៅក្នុងតំបន់ Erichem ប្រទេសហូឡង់។ គាត់គឺជាអ្នកប្រឆាំងបែបមនសិការចំពោះការបម្រើការងារយោធា និងការងារជំនួសឲ្យការងារនេះរបស់ពលរដ្ឋ ព្រមទាំងបានអះអាងថាជាជនរងគ្រោះ ដោយសាររដ្ឋាភិបាលហូឡង់ក្រោមមាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា១៤ មាត្រា១៨ និងមាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ គាត់មានមេធាវីតំណាងរបស់គាត់ ។

## អង្គហេតុដាក់ដោយដើមបណ្តឹង

**២.១** ដើមបណ្តឹងមិនបានរាយការណ៍ អំពីការបម្រើសេវាយោធារបស់គាត់ថា នៅថ្ងៃណាមួយជាក់លាក់នោះទេ។ គាត់ត្រូវបានគេចាប់ខ្លួននិងនាំទៅបន្ទាយយោធាជាទីកន្លែង ដែលគាត់បានបដិសេធក្នុងការគោរពតាមបទបញ្ជាឲ្យទទួលយកឯកសណ្ឋាន និងសម្ភារយោធា ដោយមូលហេតុថា គាត់បានបដិសេធទៅនឹងការងារយោធា និងការងារសាធារណៈជំនួស ដែលជាហេតុនាំឲ្យមានការផ្តន្ទាទោសលើស្មារតីជាអ្នកសន្តិភាពនិយមរបស់គាត់។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៧ តុលាការយោធា Arnhem បានរកឃើញថា គាត់មានពិរុទ្ធដោយការរំលោភមាត្រា២៣ និងមាត្រា១១៤ នៃក្រមព្រហ្មទណ្ឌយោធា (*Wetboek van Militair Strafrecht*) ព្រមទាំង

មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ ( *Wetboek van Strafrecht*) ហើយបានកាត់ទោសគាត់ឲ្យជាប់ពន្ធនាគារចំនួនប្រាំមួយខែ និងត្រូវបណ្ដេញចេញពីការងារជាយោធា។

**២.២** នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៧ ទាំងដើមបណ្ដឹងនិងទាំងព្រះរាជអាជ្ញា សុទ្ធតែបានប្ដឹងសាទុក្ខទៅតុលាការយោធាកំពូល ( *Hoog Militair Grechshof*) ដែលតុលាការនេះ បានរកឃើញពិរុទ្ធភាពរបស់ដើមបណ្ដឹងនៃការរំលោភមាត្រា២៣ និងមាត្រា១១៤ នៃក្រមព្រហ្មទណ្ឌយោធា ហើយបានកាត់ទោសឲ្យគាត់ជាប់ពន្ធនាគារចំនួនប្រាំមួយខែ ព្រមទាំងបានបណ្ដេញគាត់ចេញពីការងារជាយោធា។ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨៨ តុលាការកំពូលបានបដិសេធនឹងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹង។

## ខ្លឹមសារពាក្យបណ្ដឹង

**៣.១** ដើមបណ្ដឹងបានរៀបរាប់ថា ការផ្ដន្ទាទោសរបស់គាត់ គឺផ្អែកលើមាត្រា១១៤ នៃក្រមព្រហ្មទណ្ឌយោធា ដែលត្រូវអនុវត្តចំពោះទាហានមិនគោរពតាមបទបញ្ជា មិនមែនត្រូវអនុវត្តចំពោះអ្នកប្រឆាំងបែបមនសិការនោះទេ ហើយអ្នកប្រឆាំងបែបនេះ មិនអាចចាត់ទុកថាជាទាហានបែបខាងលើបានទេ។ ហេតុនេះគាត់បានអះអាងថា ការបដិសេធក្នុងការគោរពតាមបញ្ជាយោធាគឺមិនអាចត្រូវបានដាក់ទោសដោយច្បាប់បានទេ។

**៣.២** តុលាការយោធាកំពូលបានបដិសេធទៅនឹងការលើកឡើងរបស់ដើមបណ្ដឹង ដោយធ្វើការកត់សម្គាល់ថា មាត្រា១១៤ នៃក្រមព្រហ្មទណ្ឌយោធាមិនបានធ្វើការបែងចែករវាងការប្រឆាំងបែបមនសិការ និងការប្រ-

ផ្ទាំងបែបផ្សេងទៀតចំពោះការបម្រើជាយោធានោះទេ និងពិចារណាឃើញថា មាត្រា១១៤ អាចអនុវត្តបាន។

**៣.៣** ដើមបណ្ដឹងក៏បានចោទប្រកាន់ដែរថា ការរំលោភមាត្រា២៦ នៃកតិកាសញ្ញាលើមូលដ្ឋានថា អ្នកប្រឆាំងបែបមនសិការអាចត្រូវបានកាត់ទោសក្រោមក្រមព្រហ្មទណ្ឌយោធា នោះសាក្សីរបស់ Jehovah ក៏ប្រហែលជាមិនអាចរួចផុតពីការផ្ដន្ទាទោសនេះទេ។

**៣.៤** តុលាការយោធាកំពូល បានបដិសេធនឹងការលើកឡើងនេះ ដោយថ្លែងថាសាក្សីរបស់ Jehovah មិនដូចជាអ្នកប្រឆាំងបែបមនសិការ និងមិនត្រូវបានតម្រូវឲ្យធ្វើជាយោធាទេ។ ហេតុនេះ គាត់មិនអាចប្រព្រឹត្តបទល្មើសក្រោមក្រមព្រហ្មទណ្ឌយោធានេះទេ។ តុលាការយោធាកំពូលបានបន្តពិចារណាឃើញថា ខ្លួនមិនមានសមត្ថកិច្ចក្នុងការពិនិត្យមើលគោល-នយោបាយព្រាងរបស់រដ្ឋាភិបាលហូឡង់ទេ។

**៣.៥** ដើមបណ្ដឹងបានបន្តចោទប្រកាន់ទៀតថា នីតិវិធីនៅមុខតុលាការបានទទួលរងផលប៉ះពាល់ពីភាពខ្វះចន្លោះខាងនីតិវិធីផ្សេងៗ ដូចជាតុលាការមិនបានអនុវត្តច្បាប់អន្តរជាតិឲ្យបានត្រឹមត្រូវនោះទេ។

**៣.៦** ការការពារខ្លួនរបស់ដើមបណ្ដឹង គឺបានផ្អែកទៅលើការលើកឡើងថា ដោយសារការបម្រើការងារជាយោធា គាត់នឹងក្លាយទៅជាអ្នកចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយសារគាត់នឹងត្រូវគេបង្ខំឲ្យចូលរួមក្នុងការត្រៀមរៀបចំប្រើអាវុធនុយ-ក្លេអ៊ែរ។ ក្នុងបរិបទនេះ ដើមបណ្ដឹងពិចារណាឃើញថា យុទ្ធសាស្ត្ររបស់អង្គការកតិកាសញ្ញាអាត្លង់ទិចខាងត្បូង( NATO) ក៏ដូចជាផែនការប្រតិប-

ត្តិការយោធាដែរ គឺបានពឹងផ្អែកទៅលើពួកគេ ដែលនឹងជ្រើសរើសយកអាវុធនុយក្លេអ៊ែរនៅក្នុងជម្លោះប្រដាប់អាវុធ ហើយពួកគេ គឺដូចជាអ្នកសមគំនិតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និង/ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

**៣.៧** យោងទៅតាមដើមបណ្តឹង ប្រសិនបើយុទ្ធសាស្ត្ររបស់ NATO បានក្លាយទៅជាគ្រឿងការពារពីការវាយប្រហាររបស់ប្រទេសដទៃដែលអាចជឿជាក់បាន នោះមានន័យថា មេដឹកនាំនយោបាយនិងយោធាបានត្រៀមរៀបចំក្នុងការប្រើអាវុធនុយក្លេអ៊ែរក្នុងជម្លោះប្រដាប់អាវុធ។ ដើមបណ្តឹងអះអាងថា ការប្រើប្រាស់អាវុធនុយក្លេអ៊ែរជាទង្វើខុសច្បាប់។

**៣.៨** តុលាការយោធាកំពូល បានបដិសេធនឹងគំនិតការពារខ្លួនរបស់ដើមបណ្តឹង។ តុលាការបានសម្រេចថា មន្ទិលសង្ស័យពីការចូលរួមរបស់ដើមបណ្តឹងក្នុងការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពមិនបានកើតឡើងទេ ដោយសារវិធាននិងគោលការណ៍អន្តរជាតិ ដែលដើមបណ្តឹងបានលើកឡើងនៅក្នុងតុលាការមិនមានជាប់ពាក់ព័ន្ធនឹងបញ្ហា នៃការដាក់ពង្រាយអាវុធនុយក្លេអ៊ែរទេ។ ហេតុនេះ ការសមគំនិតមិនបានកើតឡើងទេ ព្រោះទ្រឹស្តីរបស់ NATO មិនត្រូវប្រើជាស្វ័យ-ប្រវត្តិ ដោយគ្មានការពិភាក្សាបន្ថែមនោះទេ។

**៣.៩** ដើមបណ្តឹងបានបន្តចោទប្រកាន់ទៀតថា តុលាការយោធាកំពូលគ្មានភាពមិនលម្អៀងតាមអត្ថន័យនៃមាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញានេះទេ។ គាត់បានពន្យល់ថា ភាគច្រើននៃសមាជិកតុលាការយោធាកំពូល គឺជាសមាជិកជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធ ដែលតាមរយៈ

សាវតារវិជ្ជាជីវៈរបស់ពួកគេ មិនអាចឲ្យគាត់រំពឹងថា ពួកគេនឹងចេញនូវដីកាមួយមិនលម្អៀងបាននោះទេ។ លើសពីនេះទៅទៀត សមាជិកស៊ីវិលនៃតុលាការយោធាកំពូលនេះ ក៏បានបម្រើការងារខ្ពស់ៗនៅក្នុងកងកម្លាំងប្រដាប់អាវុធផងដែរ ក្នុងអំឡុងពេលប្រកបការងារវិជ្ជាជីវៈរបស់ពួកគេ។

**៣.១០** ដើមបណ្តឹងក៏បានលើកឡើងពីការការពារ នៃប្រធានសក្តិ( force majeure ) ក្នុងនាមជាអ្នកប្រឆាំងបែបមនសិការទៅនឹងទម្រង់នៃការរំលោភណាមួយ ពីព្រោះគាត់មិនអាចធ្វើអ្វីមួយផ្សេងពីអ្វីដែលគាត់ចង់ធ្វើនោះទេ។ តាមរយៈការកាត់ទោសគាត់ គឺរដ្ឋភាគីបានរំលោភសិទ្ធិទទួលបានសេរីភាពសម្បជញ្ញៈរបស់គាត់។

**៣.១១** តុលាការកំពូលយោធា បានបដិសេធទៅនឹងការការពារខ្លួននេះ ដោយសំដៅទៅលើច្បាប់ស្តីពីការប្រឆាំងបែបមនសិការ ចំពោះការបម្រើការងារយោធា ដែលក្រោមច្បាប់នេះ ដើមបណ្តឹងអាចធ្វើការងារស៊ីវិលជំនួសបាន។ ប៉ុន្តែបើតាមដើមបណ្តឹង មនសិការរបស់គាត់ បានរារាំងគាត់ក្នុងការដាក់សំណើក្រោមច្បាប់ស្តីពីការប្រឆាំងបែបមនសិការចំពោះការបម្រើការងារយោធា។

**៣.១២** ទីបញ្ចប់ ដើមបណ្តឹងបានចោទពីបទរំលោភផ្សេងទៀតក្រោមមាត្រា២៦ នៃកតិកាសញ្ញានេះ ដោយមានមូលដ្ឋានថា ក្រមព្រហ្មទណ្ឌយោធា គឺមិនដូចជាក្រមព្រហ្មទណ្ឌទេ ពីព្រោះមិនមានបទប្បញ្ញត្តិចែងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការកោះហៅ។ តាមដើមបណ្តឹង វាជារឿងចម្លែកដែលពលរដ្ឋក្លាយទៅជាយោធានឹងត្រូវបានគេរើសអើងបើធៀបទៅនឹងពលរដ្ឋដទៃទៀត។

## ការពិនិត្យអង្កេត និងការបញ្ជាក់របស់ដើមបណ្ដឹង

**៤.១** រដ្ឋភាគីកត់សម្គាល់ឃើញថា សិទ្ធិរបស់រដ្ឋមួយក្នុងការតម្រូវឲ្យពលរដ្ឋរបស់ខ្លួនបំពេញកាតព្វកិច្ចយោធា ឬកាតព្វកិច្ចជំនួសក្នុងករណីនៃអ្នកប្រឆាំងបែបមនសិការ ដែលមូលដ្ឋាននៃការប្រឆាំងរបស់ពួកគេត្រូវបានទទួលស្គាល់ដោយរដ្ឋបែបនេះ គឺមិនត្រូវបានជំទាស់ឡើយ។ សេចក្ដីយោងគឺត្រូវបានបង្កើតឡើងនៅក្នុងមាត្រា៨ កថាខណ្ឌទី៣(គ)(ii) នៃកតិកាសញ្ញានេះ។

**៤.២** រដ្ឋភាគីថ្លែងថា សាក្សីរបស់ Jehovah ត្រូវបានរួចផុតពីការបម្រើការងារយោធាតាំងពីឆ្នាំ១៩៧៤។ ការធ្វើវិសោធនកម្មច្បាប់ ស្ដីពីការធ្វើកំណែនទ័ពត្រូវបានរៀបចំ ដើម្បីបង្កើតបទប្បញ្ញត្តិសម្រាប់ជំនុំជម្រះ "អ្នកប្រឆាំងទាំងអស់" បានបន្តធ្វើឲ្យសាក្សីរបស់ Jehovah រួចខ្លួន។ ជាទស្សនៈរបស់រដ្ឋាភិបាល ភាពជាសមាជិកនៃសាក្សីរបស់ Jehovah បង្កើតឲ្យមានភស្ដុតាងរឹងមាំបញ្ជាក់ថា ការប្រឆាំងទៅនឹងការបម្រើការងារយោធាត្រូវបានផ្អែកទៅលើការដាក់ទោសតាមបែបសាសនា។ ហេតុដូច្នេះ ពួកគេមានលក្ខណៈជាស្វ័យប្រវត្តិ សម្រាប់ការរួចផុតពីការងារនេះ។ ទោះបីជាយ៉ាងណានេះ គឺមិនបានដកចេញនូវលទ្ធភាពសម្រាប់បុគ្គលដទៃទៀតក្នុងការលើកយកច្បាប់ ស្ដីពីការប្រឆាំងបែបមនសិការ ចំពោះការបម្រើការងារយោធាមកប្រើនោះទេ។

**៤.៣** រដ្ឋាភិបាលយល់ឃើញថា ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការយោធាកំពូលក្នុងប្រទេសហូឡង់ ត្រូវបានធានាដោយនីតិវិធី និងបទប្បញ្ញត្តិដូចតទៅ៖

(ក) ប្រធាននិងសមាជិកគណៈវិនិច្ឆ័យ នៃតុលាការយោធាកំពូល គឺជាចៅក្រមនៅក្នុងសាលាឧទ្ធរណ៍(*Gerechtshof*) ហើយនឹងនៅតែជាប្រធាននិងសមាជិកគណៈវិនិច្ឆ័យ ដរាបណាពួកគេគឺជាសមាជិកនៃសាលាឧទ្ធរណ៍។

(ខ) សមាជិករបស់តុលាការយោធាកំពូលជាយោធា ត្រូវបានតែងតាំងដោយព្រះរាជា។ ពួកគេនឹងត្រូវលាលែងពីតំណែងនៅអាយុ ៧០ឆ្នាំ។

(គ) សមាជិក នៃតុលាការយោធាកំពូលជាយោធា មិនមានកាន់កាប់មុខតំណែងក្នុងឋានានុក្រមយោធាទេ។ ប្រាក់ខែរបស់ពួកគេត្រូវបានចំណាយដោយក្រសួងយុត្តិធម៌។

(ឃ) ប្រធាននិងសមាជិក នៃតុលាការយោធាកំពូល ត្រូវតែស្បថមុនពេលទទួលយកការតែងតាំងរបស់ខ្លួន។ ពួកគេស្បថ ឬសច្ចាថាធ្វើការងារដោយយុត្តិធម៌ និងមិនលម្អៀង។

(ង) ប្រធាននិងសមាជិក នៃតុលាការយោធាកំពូលមិនស្ថិតនៅក្រោមគំនាបនរណាម្នាក់ ហើយពួកគេក៏គ្មានការទទួលខុសត្រូវចំពោះនរណាម្នាក់ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចចិត្តរបស់ខ្លួនដែរ។

(ច) ជាគោលការណ៍ការពិភាក្សារបស់តុលាការយោធាកំពូល គឺធ្វើជាសាធារណៈ។

**៤.៤** រដ្ឋភាគី បានចង្អុលបង្ហាញថា សាលក្រមថ្នាក់ជាតិ និងថ្នាក់អន្ត-រជាតិបានបញ្ជាក់ពីភាពមិនលម្អៀង និងឯករាជ្យភាព របស់តុលាការយោធាក្នុងប្រទេសហូឡង់។ អំណះអំណាងត្រូវបានបង្កើតឡើងលើករណី Engel របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងសាលក្រមរបស់តុលាការកំពូលប្រទេសហូឡង់ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨៤។

**៤.៥** ពាក់ព័ន្ធនឹងការប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឲ្យអស់លទ្ធ-ភាព រដ្ឋភាគីអះអាងថា ច្បាប់ស្ដីពីការប្រឆាំងបែបមនសិការចំពោះការបម្រើការងារយោធា គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយលើការប្រឆាំងចំពោះការបម្រើការងារយោធា ដែលមិនអាចទទួលបានជោគជ័យ។ រដ្ឋភាគីថ្លែងថា ដោយសារតែដើមបណ្ដឹងមិនបានលើកយកច្បាប់នេះមកប្រើ ដូចនេះ គាត់បានខកខានក្នុងការប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឲ្យអស់ពីលទ្ធភាព។

**៤.៦** ចំពោះការចោទប្រកាន់ពាក់ព័ន្ធទៅនឹងអវត្តមាន នៃសិទ្ធិប្ដឹងឧទ្ធរ-ណ៍ប្រឆាំងនឹងការកោះហៅដំបូងរដ្ឋាភិបាល បានយោងលើសេចក្ដីសម្រេចពីភាពអាចទទួលយកបានដោយគណៈកម្មាធិការសិទ្ធិមនុស្ស លើបណ្ដឹងលេខ២៦៧/១៩៨៧ និងបណ្ដឹងលេខ២៤៥/១៩៨៧ ដែលបានលើកឡើងនូវបញ្ហាដូចគ្នា។ ហេតុដូច្នេះ រដ្ឋាភិបាលយល់ថា បណ្ដឹងលើផ្នែកនេះគួរតែទំនងជាមិនអាចទទួលយកបានទេ។

**៤.៧** រដ្ឋភាគីថ្លែងថា ផ្នែកដទៃទៀតនៃបណ្ដឹងរបស់ដើមបណ្ដឹងគ្មានភ័ស្ដុតាងបញ្ជាក់ទេ។ ដោយសន្និដ្ឋានថា ដើមបណ្ដឹងមិនបានធ្វើការប្ដឹងក្រោមមាត្រា២ នៃពិធីសារបន្ថែម និងថាបណ្ដឹងរបស់គាត់គួរតែត្រូវបានប្រកាសថា មិនអាចទទួលយកបានទេ។

**៥.១** ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់រដ្ឋភាគី ដើមបណ្ដឹងអះអាងថា ច្បាប់ស្ដីពីការប្រឆាំងបែបមនសិការមានវិសាលភាពដែលមានដែនកំណត់និងថាច្បាប់នេះអាចលើកយកមកប្រើបានតែសម្រាប់កំណែនណា ដែលបានបំពេញទៅតាមលក្ខខណ្ឌក្នុងផ្នែកទី២ នៃច្បាប់នេះប៉ុណ្ណោះ។

ដើមបណ្ដឹងបដិសេធទៅនឹងការលើកឡើងថា ផ្នែកទី២នេះ មានវិសាលភាពទូលំទូលាយគ្រប់គ្រាន់គ្របដណ្ដប់លើការប្រឆាំង ដែលបានអះអាងដោយ "អ្នកប្រឆាំងទាំងអស់" ទៅនឹងការធ្វើកំណែនកងទ័ព និងការបម្រើការងារស៊ីវិលជំនួស។ គាត់លើកឡើងថា សំណួរមិនមែនថា តើដើមបណ្ដឹងគួរតែលើកយកច្បាប់ស្ដីពីការប្រឆាំងបែបមនសិការមកប្រើឬក៏អត់នោះទេ។ តែត្រូវសួរថា តើរដ្ឋភាគីមានសិទ្ធិបង្ខំដើមបណ្ដឹងឲ្យក្លាយទៅជាអ្នកសមគំនិតក្នុងអំពើឧក្រិដ្ឋប្រឆាំងសន្តិភាព ដោយការតម្រូវឲ្យគាត់ចូលបម្រើការងារយោធាដែរឬទេ?

**៥.២** ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឲ្យអស់លទ្ធភាព ដើមបណ្ដឹងបានពន្យល់ថា គាត់ត្រូវបានផ្ដន្ទាទោសដោយសាលាដំបូង និងថាបណ្ដឹងឧទ្ធរណ៍ទៅតុលាការយោធាកំពូលនិងតុលាការកំពូលរបស់គាត់ត្រូវបានបដិសេធ។ ហេតុនេះ គាត់លើកឡើងថា តម្រូវការឲ្យប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឲ្យអស់លទ្ធភាព គឺគាត់បានគោរពតាមយ៉ាងពេញលេញ។

**៥.៣** ពាក់ព័ន្ធនឹងសំណើធ្វើវិសោធនកម្មច្បាប់ ស្ដីពីកំណែនកងទ័ពរបស់រដ្ឋភាគីដើមបណ្ដឹងអះអាងថា មាត្រាមួយចំនួននឹងត្រូវបានដកចេញ។

**៥.៤** ដើមបណ្ដឹងពន្យល់ថា រដ្ឋភាគីមិនអាចអះអាងថាតុលាការសិទ្ធិមនុស្សអឺរ៉ុប បានបញ្ជាក់ពីឯករាជ្យភាពនិងភាពមិនលម្អៀង នៃនីតិវិធីអាជ្ញាសឹករបស់តុលាការហូឡង់ (តុលាការយោធា) បានទេ។

## សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន របស់គណៈកម្មាធិការ

**៦.១** ក្នុងអំឡុងពេលនៃសម័យប្រជុំលើកទី៤៤ របស់ខ្លួន គណៈកម្មា-ធិការបានធ្វើការពិនិត្យទៅលើភាពអាចទទួលយកបាននៃបណ្តឹងនេះ។ គណៈកម្មាធិការបានពិចារណាឃើញថា ចាប់តាំងពីដើមបណ្តឹងត្រូវបានផ្តន្ទាទោសពីបទបដិសេធក្នុងការគោរពតាមបទបញ្ជាយោធា ហើយបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការកាត់ទោសរបស់គាត់ ត្រូវបានច្រានចោលដោយតុលាការកំពូលហូឡង់ គឺបណ្តឹងនេះ បានបំពេញទៅតាមលក្ខខណ្ឌនៃមាត្រា៥ កថាខណ្ឌទី២(ខ) នៃពិធីសារបន្ថែមរួចហើយ។

**៦.២** គណៈកម្មាធិការ ពិចារណាឃើញថា ការអះអាងរបស់ដើមបណ្តឹងដែលថា តុលាការបានបកស្រាយច្បាប់ខុស និងបានកាត់ទោសគាត់ដោយខុសឆ្គង ក៏ដូចជាការអះអាងរបស់គាត់ក្រោមមាត្រា៦ មាត្រា៧ គឺមិនអាចទទួលយកបានទេ តាមមាត្រា៣ នៃពិធីសារបន្ថែម។ ពាក់ព័ន្ធទៅនឹងការអះអាងរបស់ដើមបណ្តឹងថា សិទ្ធិរបស់គាត់ក្រោមមាត្រា២៦ នៃកតិ-កាសញ្ញានេះត្រូវបានរំលោភ ពីព្រោះក្រមព្រហ្មទណ្ឌយោធាមិនដូចនឹងក្រមព្រហ្មទណ្ឌ ដោយសារមិនមានបទប្បញ្ញត្តិណាអនុញ្ញាតឲ្យមានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាកោះទេ។ គណៈកម្មាធិការបានសំដៅទៅដល់យុត្តិសាស្ត្ររបស់ខ្លួនក្នុងសំណុំរឿងលេខ២៤៥/១៩៨៧ និងលេខ២៦៧/១៩៨៧ និងបានពិនិត្យឃើញថា វិសាលភាពនៃមាត្រា២៦ មិនអាចពង្រីកឲ្យគ្របដណ្តប់ទៅលើស្ថានភាពមួយ ដូចដែលដើមបណ្តឹងបានជួបប្រទះបានទេ។ ហេតុដូច្នេះ បណ្តឹងផ្នែកនេះត្រូវបានប្រកាសថា មិនអាចទទួលយកបានទេ

អនុលោមតាមមាត្រា២ នៃពិធីសារបន្ថែម។

**៦.៣** គណៈកម្មាធិការបានសម្រេចថា ការចោទប្រកាន់របស់ដើមបណ្ដឹង ពាក់ព័ន្ធនឹងការធ្វើឲ្យមានភាពខុសគ្នារវាងសាក្សីរបស់ Jehovah និងអ្នកប្រឆាំងបែបមនសិការ ទៅនឹងការបម្រើការងារយោធា និងការងារជំនួសជាទូទៅគួរតែត្រូវបានពិនិត្យទៅលើអង្គសេចក្ដី។

**៦.៤** គណៈកម្មាធិការបានពិនិត្យឃើញថា ការអះអាងផ្សេងទៀតរបស់ដើមបណ្ដឹងគឺមិនមានភ័ស្ដុតាងបញ្ជាក់ទេ។ ហេតុនេះ មិនអាចទទួលយកបានទេក្រោមមាត្រា២ នៃពិធីសារបន្ថែម។

**៦.៥** ដូច្នេះ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩២ គណៈកម្មាធិការបានប្រកាសថាបណ្ដឹងនេះ គឺអាចទទួលយកបាន ដោយសារតែការធ្វើឲ្យមានភាពខុសគ្នាក្នុងការប្រព្រឹត្តរវាងសាក្សីរបស់ Jehovah និងអ្នកប្រឆាំងបែបមនសិការ ដែលជាទូទៅអាចបង្កើតជាបញ្ហាផ្សេងៗ ក្រោមមាត្រា២៦ នៃកតិកាសញ្ញានេះ។

## សេចក្ដីសន្និដ្ឋានរបស់រដ្ឋភាគីទៅលើអង្គសេចក្ដី និង យោបល់របស់ដើមបណ្ដឹង

**៧.១** នៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩២ រដ្ឋភាគីបានលើកឡើងថា ភាពខុសគ្នារវាងសាក្សីរបស់ Jehovah និងអ្នកប្រឆាំងបែបមនសិការដទៃទៀត ចំពោះបម្រើការងារយោធាគឺផ្អែកទៅលើកម្មវត្ថុ និងលក្ខណៈវិនិច្ឆ័យមួយប្រកបដោយហេតុផល។

**៧.២** ដោយយោងទៅតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ រដ្ឋភាគីពន្យល់ថា ការផ្អាកនៃការហ្វឹកហ្វឺនដំបូងអាចត្រូវបានផ្តល់ឲ្យក្នុងករណីជាក់លាក់ពេលដែលមានកាលៈទេសៈពិសេស។ សាក្សីម្នាក់របស់ Jehovah ដែលបានទទួលសិទ្ធិសម្រាប់បម្រើការងារយោធា ជាវិធានមួយនឹងត្រូវបានផ្អាកការហ្វឹកហ្វឺនដំបូង ប្រសិនបើសហគមន៍របស់គាត់ផ្តល់នូវការធានាថា គាត់ជាសមាជិកដែលបានបញ្ចូលក្នុងសាសនា។ រដ្ឋភាគីសន្និដ្ឋានថា ការផ្អាកនេះនឹងត្រូវដកចេញ ប្រសិនបើសហគមន៍បានជូនដំណឹងទៅក្រសួងការពារជាតិថា ជនដែលពាក់ព័ន្ធមិនមែនជាសមាជិកពេញលេញម្នាក់របស់សហគមន៍បន្តទៀតទេ។ ប្រសិនបើមូលដ្ឋានសម្រាប់ការផ្អាកនៅបន្តអនុវត្តការចូលបម្រើការងារយោធានឹងត្រូវហួលកាលកំណត់នៅពេលដែលបុគ្គលនោះមានអាយុ ៣៥ឆ្នាំ។

**៧.៣** ដើម្បីពន្យល់ពីការប្រព្រឹត្តពិសេសចំពោះសាក្សីរបស់ Jehovah រដ្ឋភាគីថ្លែងថាសមាជិកដែលបានបញ្ចូលក្នុងសាសនា បង្កើតបានជាក្រុមដ៏ជិតស្និទ្ធមួយ នៃមនុស្សដែលត្រូវទទួលកាតព្វកិច្ចពិនិត្យមើលវិធាន នៃអាកប្បកិរិយាដ៏មុឹងម៉ាត់ ដែលអាចអនុវត្តបានចំពោះទិដ្ឋិភាពជាច្រើន នៃជីវិតប្រចាំថ្ងៃរបស់ពួកគេនិងត្រូវត្រួតពិនិត្យពីសង្គមយ៉ាងហ្មត់ចត់។ យោងតាមរដ្ឋភាគីវិធានមួយនៃវិធានទាំងនេះ បានហាមឃាត់ការចូលរួមក្នុងប្រភេទណាមួយនៃការងារយោធា និងការងារជំនួស។ ពេលដែលវិធានដទៃទៀតតម្រូវឲ្យសមាជិកទាំងអស់ត្រូវតែមានវត្តមានជាអចិន្ត្រៃយ៍ក្នុងគោលបំណងផ្សព្វផ្សាយលទ្ធិសាសនា។

៧.៤ រដ្ឋភាគីបានធ្វើសេចក្តីសន្និដ្ឋានថា ការប្រព្រឹត្តខុសគ្នាលើសាក្សីរបស់ Jehovah មិនបានបង្កើតជាការរើសអើងប្រឆាំងនឹងដើមបណ្តឹងទេ ពីព្រោះការប្រព្រឹត្តនេះ បានផ្អែកទៅលើគោលបំណង និងលក្ខណៈវិនិច្ឆ័យប្រកបដោយហេតុផល។ ក្នុងទំនាក់ទំនងនេះរដ្ឋភាគីសំដៅដល់ច្បាប់យុត្តិ-សាស្ត្ររបស់គណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ លើសពីនេះទៅទៀត រដ្ឋភាគីបានលើកឡើងថា ដើមបណ្តឹងមិនបានបញ្ជាក់ថា ខ្លួនគាត់ស្ថិតនៅក្នុងស្ថានភាពដូចគ្នាទៅនឹងសាក្សីរបស់ Jehovah ទេ។

៨. នៅក្នុងយោបល់របស់គាត់ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៣ ទៅលើសេចក្តីសន្និដ្ឋានរបស់រដ្ឋភាគីដើមបណ្តឹងលើកឡើងថា ខណៈដែលរដ្ឋភាគីបានទទួលយកភាពជាសមាជិក នៃសាក្សីរបស់ Jehovah ថាជាការបញ្ជាក់ដ៏គ្រប់គ្រាន់សម្រាប់ការប្រឆាំងទៅនឹងការចូលធ្វើជាយោធា និងការងារជំនួសគឺជាការពិតជាក់ស្តែង។ ប៉ុន្តែរដ្ឋភាគីមិនបានទទួលស្គាល់ការប្រឆាំងដែលមិនអាចជម្នះបានរបស់មនុស្សដទៃទៀត ដោយបានផ្អែកទៅលើភាពរឹងមាំស្មើគ្នា និងការកាត់ទោសដោយត្រឹមត្រូវទេ។ ដោយសារតែការរួចផុតពីការចូលធ្វើជាយោធា និងការងារជំនួយ នៃសាក្សីរបស់ Jehovah ដើមបណ្តឹងលើកឡើងថា រដ្ឋភាគីបានការពារពួកគេប្រឆាំងនឹងការដាក់ទោស ដោយអង្គភាពរបស់ពួកគេផ្ទាល់ ខណៈដែលអ្នកប្រឆាំងដទៃទៀតត្រូវបញ្ជូនទៅពន្ធនាគារ។ គាត់បន្តលើកឡើងថា ការបញ្ជូនអ្នកប្រឆាំងទាំងអស់ទៅពន្ធនាគាររួចជាស្រេច បង្កើតបានជាភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីភាពស្មោះត្រង់នៃការប្រឆាំងនិងបានអះអាងថា ភាពខុសគ្នាក្នុងការប្រព្រឹត្តរវាងសាក្សីរបស់ Jehovah និងអ្នកប្រឆាំងបែបមនសិការដទៃទៀត គឺស្មើទៅនឹងការរើសអើង អនុលោមតាមមាត្រា២៦ នៃកតិកាសញ្ញានេះ។

## ការពិនិត្យមើលលើអង្គសេចក្តី

**៩.១** គណៈកម្មាធិការ បានពិនិត្យឃើញថា បណ្តឹងនេះគឺស្របគ្នាទៅតាមព័ត៌មានដែលរដ្ឋភាគីបានបញ្ជូនមកដូចមានចែងក្នុងមាត្រា៥ កថាខណ្ឌទី១ នៃពិធីសារបន្ថែម។

**៩.២** បញ្ហានៅចំពោះមុខគណៈកម្មាធិការ គឺថាតើភាពខុសគ្នាក្នុងការប្រព្រឹត្តពាក់ព័ន្ធនឹងការរួចផុតពីការចូលធ្វើយោធារវាងសាក្សីរបស់ Jehovah និងអ្នកប្រឆាំងបែបមនសិការដទៃទៀត ស្មើទៅនឹងការរើសអើង ដែលត្រូវបានហាមឃាត់ក្រោមមាត្រា២៦ នៃកតិកាសញ្ញានេះឬទេ? គណៈកម្មាធិការបានកត់សម្គាល់ពីការលើកឡើងរបស់រដ្ឋភាគីដែលថា ភាពខុសគ្នានេះបានផ្អែកទៅលើគោលបំណង និងការវិនិច្ឆ័យប្រកបដោយហេតុផល ពីព្រោះសាក្សីរបស់ Jehovah បានបង្កើតជាក្រុមសង្គមមួយដ៏ជិតស្និទ្ធជាមួយនឹងវិជានខាងអាកប្បកិរិយាដ៏ម៉ឺងម៉ាត់។ ភាពជាសមាជិកនៃក្រុមនេះ ត្រូវបានគេនិយាយថា បង្កើតឲ្យបានជាភ័ស្តុតាងបញ្ជាក់ដ៏រឹងមាំ ពីការប្រឆាំងទៅនឹងការចូលធ្វើយោធា និងការងារជំនួស ដោយផ្អែកទៅលើការដាក់ទោសតាមបែបសាសនាដ៏ត្រឹមត្រូវ។ គណៈកម្មាធិការ កត់សម្គាល់ថា មិនមានលទ្ធភាពផ្លូវច្បាប់សម្រាប់ឲ្យអ្នកប្រឆាំងបែបមនសិការដទៃទៀត រួចផុតពីការបម្រើការងារនេះទេ។ ពេលដែលពួកគេបដិសេធធ្វើការងារនោះ ដោយហេតុផលមនសិការ ពួកគេត្រូវមានទោស ហើយប្រសិនបើត្រូវបានកាត់ទោសពួកគេនឹងត្រូវកាត់ឲ្យជាប់ពន្ធនាគារ។

៩.៣ *គណៈកម្មាធិការពិនិត្យឃើញថា ការរួចផុតពីការបម្រើការងារនេះ សម្រាប់តែក្រុមនៃអ្នកប្រឆាំងបែបមនសិការមួយក្រុម និងមិនសម្រាប់ក្រុមដទៃទៀត មិនអាចថាជាការសមហេតុផលបានទេ។* ក្នុងបរិបទនេះ គណៈកម្មាធិការសំដៅដល់យោបល់ទូទៅរបស់ខ្លួនលើមាត្រា១៨ និងបានសង្កត់ធ្ងន់ថា *ពេលដែលសិទ្ធិនៃការប្រឆាំងបែបមនសិការ ចំពោះការចូលធ្វើយោធាត្រូវបានទទួលស្គាល់ដោយរដ្ឋភាគី គ្មានភាពខុសគ្នាណាមួយត្រូវបានបង្កើតឡើងក្នុងចំណោមអ្នកប្រឆាំងបែបមនសិការនោះ ដោយផ្អែកលើលក្ខណៈ នៃជំនឿពិសេសរបស់ពួកគេទេ។ ប៉ុន្តែក្នុងករណីនេះ គណៈកម្មា-ធិការពិនិត្យឃើញថា ដើមបណ្ដឹងមិនបានបង្ហាញថា ការកាត់ទោសរបស់គាត់ដែលដូចជាអ្នកសន្តិភាពនិយមម្នាក់ ជាទង្វើផ្ទុយទៅនឹងប្រព័ន្ធការងារជំនួសក្នុងប្រទេសហូឡង់ ឬថា ការប្រព្រឹត្តដោយផ្ដល់អភ័យឯកសិទ្ធិទៅឲ្យសាក្សីរបស់ Jehovah នាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិរបស់គាត់ក្នុងនាមជាអ្នកប្រឆាំងបែបមនសិការម្នាក់ទៅនឹងការចូលធ្វើយោធានោះទេ។* ហេតុដូចនេះ គណៈកម្មាធិការរកឃើញថា លោក Brinkhof មិនមែនជាជនរងគ្រោះក្រោមមាត្រា២៦ នៃកតិកាសញ្ញានេះទេ។

៩.៤ *ប៉ុន្តែគណៈកម្មាធិការបានបញ្ចេញយោបល់ថា រដ្ឋភាគីគួរតែផ្ដល់នូវការប្រព្រឹត្តឲ្យបានស្មើគ្នា ចំពោះមនុស្សទាំងអស់ ដែលប្រកាន់ខ្ជាប់នូវការប្រឆាំងយ៉ាងរឹងមាំដូចគ្នា ចំពោះការចូលធ្វើយោធា និងការងារជំនួស។ គណៈកម្មាធិការបានផ្ដល់ជាអនុសាសន៍ឲ្យរដ្ឋភាគីពិនិត្យមើលច្បាប់ និងការអនុវត្តន៍ទាំងឡាយរបស់ខ្លួនដែលពាក់ព័ន្ធក្នុងន័យលុបបំបាត់នូវការរើសអើង។*